ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ៣៤ អនក្រ.បក

********

# អនុក្រឹត្យ

## ស្តីពី

## ល័ក្ខខណ្ឌ និង នីតិវិធី ក្នុងការគ្រប់គ្រង កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះដែលត្រូវបានអនុញ្ញាតឱ្យជនស៊ីវិលប្រើប្រាស់

*********

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដាឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

-បានឃើញអនុក្រឹត្យលេខ១៦ អនក្រ-បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៩ ស្តីពីគ្រប់គ្រង និងការត្រួត ពិនិត្យ ការនាំចូល ការផលិត ការលក់ ការទិញដូរ ការចែកចាយ និង ការប្រើប្រាស់អាវុធជាតិផ្ទុះ គ្រប់ ប្រភេទ

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.~**

អនុក្រឹត្យនេះ មានគោលដៅកំណត់ពីល័ក្ខខ័ណ្ឌ និង នីតិវិធីក្នុងការគ្រប់គ្រងកាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដែលត្រូវបាន

អនុញ្ញាតឱ្យជនស៊ីវិលប្រើប្រាស់ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការគ្រប់គ្រង អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ដែលប្រកាសដោយព្រះរាជក្រម លេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី០១ ខែ មិថុនា ឆ្នាំ ២០០៥។

**មាត្រា ២.~**

អនុក្រឹតនេះមានគោលបំណងការពារសន្តិសុខ សុវត្ថិភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ។

**មាត្រា ៣.~**

វិសាភាព នៃអនុក្រឹត្យនេះគ្របដណ្តប់លើ ការកាន់កាប់ ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជ កម្ម ការចែកចាយ ការឱ្យខ្ចី ការជួល ការផលិត ការកែច្នៃដំឡើង ការដឹកជញ្ជូន ការនាំចូល ការនាំចេញ ការនាំ ឆ្លងកាត់ ការស្តុកកាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះដែលត្រូវបានអនុញ្ញាតឱ្យជនស៊ីវិលប្រើប្រាស់។

**មាត្រា ៤.~**

វាក្យសព្ទ ដូចចែងក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចខាងក្រោម៖

ក. កាំភ្លើងកំណត់សញ្ញា ៖ សំដៅដល់ កាំភ្លើងខ្លី ឬ វែងដែលគេផលិតឡើងក្នុងគោលបំណងដើម្បីបាញ់ចេញ បន្លឺសំឡេង ឬ ចេញភ្លើង ផ្សែង សម្រាប់កំណត់សញ្ញា ឬ ទីកន្លែង។

ខ. កាំភ្លើងកីឡា ៖ សំដៅដល់ កាំភ្លើងខ្លី ឬ វែងដែលគេផលិតឡើងក្នុងគោលបំណង ដើម្បីហាត់ហ្វឹកហ្វឺន ឬ ប្រកួតក្នុង សកម្មភាពកីឡា។

គ. កាំភ្លើងសិល្បៈ ៖ សំដៅដល់កាំភ្លើងដែលផលិតឡើងក្នុងគោលបំណងប្រើប្រាស់សម្រាប់ការសំដែងសិល្បៈអាចបាញ់ចេញ បន្លឺសម្លេង ឬ អណ្តាតភ្លើងតែគ្មានក្បាលគ្រាប់។

ឃ. បំពង់ និងគ្រាប់កាំជ្រួចផ្ទុះលម្អ ៖ សំដៅដល់ ឧបករណ៍ដែលគេផលិតឡើង ក្នុងគោលបំណងដើម្បីបាញ់ បញ្ជូនគ្រាប់កាំជ្រួចទៅលើអាកាស ផ្ទុះបន្លឺសម្លេង និង/ឬ បែកចេញផ្កាភ្លើង គ្មានបំណែកអម្បែងលោហៈ។

ង. គ្រាប់បាញ់ ៖ សំដៅដល់ គ្រាប់ ឬកិបសម្រាប់បាញ់ជាមួយកាំភ្លើងដូចបានចែងក្នុងកថាខណ្ឌ ក.ខ.គ និង ឃ។

ច. គ្រឿងផ្ទុះ ៖ សំដៅដល់ កិបផ្ទុះ ខ្សែឆ្នួនផ្ទុះ ខ្សែឆ្នួនឆេះ រំសេវ ជាតិផ្ទុះ និង សារធាតុផ្ទុះ គ្រប់ប្រភេទ ទោះជាមានដើម កំណើតពីអ្វីក៏ដោយសម្រាប់បម្រើសេវាកម្មសាធារណៈ និងវិស្វកម្មស៊ីវិល ឬ ផ្ទុះលម្អ។

## ជំពូកទី ២

## លក្ខខណ្ឌ និង នីតិវិធី

## ក្នុងការគ្រប់គ្រង និងការអនុញ្ញាតឱ្យប្រើប្រាស់

**មាត្រា ៥.~**

កាំភ្លើង គ្រាប់បាញ់ និង គ្រឿងផ្ទុះ ដូចបានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះត្រូវចុះបញ្ជីគ្រប់គ្រងតាមគំរូឯកភាពកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៦.~**

លក្ខខណ្ឌក្នុងការអនុញ្ញាតឱ្យប្រើប្រាស់កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដូចបានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះត្រូវកំណត់ដូចខាងក្រោម៖

- អ្នកស្នើសុំត្រូវជារូបវន្តបុគ្គល ដែលមានសញ្ជាតិខ្មែរ មានអាយុ ១៨ ឆ្នាំឡើង និងមាននីតិសម្បទាគ្រប់គ្រាន់ ឬនីតិបុគ្គដែលមានសញ្ជាតិខ្មែរ ដែលបានបំពេញបែបបទ និងចុះបញ្ជីត្រឹមត្រូវតាមច្បាប់។
- គោលបំណង និងសំណូមពរ នៃការស្នើសុំ ត្រូវស្របនឹងភាពចាំបាច់ក្នុងមុខរបរ ជាអាជីព ឬវិជ្ជាជីវៈ។
- កាំភ្លើង គ្រាប់បាញ់ ឬគ្រឿងផ្ទុះត្រូវបានផលិតឡើងត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស មានប្រវត្តិ និងអត្តសញ្ញាណច្បាស់លាស់។
- មានការធានាទទួលខុសត្រូវលើផលវិបាកផ្សេងៗដែលកើតមានឡើង។
- គោរពការណែនាំរបស់ក្រសួងមានសមត្ថកិច្ចពីវិធាននានា ក្នុងការគ្រប់គ្រង ឬកិច្ចការពារសុវត្ថិភាពនិរភ័យក្នុងការដឹកជញ្ជូនការស្តុក និងការបញ្ចេញប្រើប្រាស់។
- បំពេញកាតព្វកិច្ចផ្សេងទៀតដែលច្បាប់បានកំណត់។

**មាត្រា ៧.~**

នីតិវិធីក្នុងការស្នើសុំលិខិតអនុញ្ញាត ឬ ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់កាំភ្លើងគ្រាប់បាញ់ និងគ្រឿងផ្ទុះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៨.~**

បរិមាណ ប្រភេទ គុណភាពកាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះដែលត្រូវផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់ ស្របតាមលក្ខខណ្ឌដូចបានចែងក្នុងមាត្រា ៦ នៃអនុក្រិត្យនេះ ត្រូវពិនិត្យសម្រេចដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៩.~**

កាំភ្លើង គ្រាប់បាញ់ ឬគ្រឿងផ្ទុះ និងលិខិតអនុញ្ញាតទាំងឡាយ ឬបណ្ណសម្គាល់សិទ្ធិប្រើប្រាស់ត្រូវតែបង្ហាញដល់ភ្នាក់ងារមានសមត្ថកិច្ចនៅមានសំណូមពរត្រួតពិនិត្យ។

## ជំពូកទី ៣
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ១០.**~

ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការចែកចាយ ការជួល ការផលិត ការកែច្នៃដំឡើង ការដឹកជញ្ជូន ការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការស្តុកកាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះដូចបានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ១១.**~

ការផ្គត់ផ្គង់ ការត្រួតពិនិត្យ ការគ្រប់គ្រងគ្រឿងផ្ទុះ សម្រាប់សម្រេីសេវាកម្មសាធារណៈ និងវិស្វកម្មស៊ីវិល ដូចបានចែងក្នុងកថាខណ្ឌ ច មាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវទទួលខុសត្រូវដោយក្រសួងមហាផ្ទៃ។

**មាត្រា ១២.**~

ការដឹកជញ្ជូនគ្រឿងផ្ទុះសម្រាប់បម្រើសេវាកម្មសាធារណៈ និង វិស្វកម្មស៊ីវិលត្រូវមានលិខិតអនុញ្ញាតពី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មធ្យោបាយដឹកជញ្ជូន និង ការពារសុវត្ថភាព នរភ័យ ត្រូវរ៉ាប់រងដោយកងកម្លាំងនគរបាលជាតិ។

**មាត្រា ១៣.**~

ឃ្លាំងស្តុកគ្រឿងផ្ទុះត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌបច្ចេកទេសអំពីប្រព័ន្ធការពារសុវត្ថិភាព និរភ័យដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ១៤.**~

ស្ថាប័នសាធារណៈ អង្គការប្រតិបត្តិករ ក្រុមហ៊ុន ការដ្ឋាន កសិដ្ឋាន សិប្បកម្មដ្ឋាន និង អតិថិជនដែលមានតម្រូវការប្រើប្រាស់គ្រឿងផ្ទុះត្រូវសុំអាជ្ញាប័ណ្ណពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូក ៤
## ទោសប្បញ្ញត្តិ

**មាត្រា ១៥.**~

ជនណា ដែលផ្ទុយពីខ្លឹមសារ នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**មាត្រា ១៦.~**

ក្នុងរយៈពេល ៣ (បី) ខែ យ៉ាងយូរ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ជនណាដែលបានកាន់កាប់ កាំភ្លើង គ្រាប់បាញ់ និង គ្រឿងផ្ទុះ ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវយកចុះបញ្ជីនៅក្រសួងមហាផ្ទៃជាកំហិត។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៧.~**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ១៨.~**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលគ្រប់ខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្ត